**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ២៣២២ ដនស/អរប.

ថ្ងៃអង្គារ ៧រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៩

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ ៖** វិធានការចំពោះក្រុមហ៊ុនប្រកបអាជីវកម្មសាងសង់ និងម្ចាស់សំណង់ដែលមិនអនុវត្តតាមកាតព្វកិច្ច និងលក្ខខណ្ឌតម្រូវដោយបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេស

**យោង ៖**
- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- ប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់
- ប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- ប្រកាសលេខ ១៦៦ ប្រក/ដនស ចុះថ្ងៃទី ០៨ ខែតុលា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលប្រការ ៧ និងប្រការ ១០ នៃប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់
- សារាចរណែនាំលេខ ០០២ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០០ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់របស់សហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គលបរទេស

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល** ជ្រាបថា ដើម្បីធានាការងារសំណង់ ការប្រើប្រាស់សំណង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានគតិយុត្តនិងបទដ្ឋានបច្ចេកទេសសំណង់ ធានាគុណភាព សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិ សុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់និងសាធារណជន និងធានាគណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសាងសង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្នើ **ឯកឧត្តម លោកជំទាវអភិបាល** ចាត់វិធានការតាមផ្លូវច្បាប់ចំពោះក្រុមហ៊ុនសាងសង់ដែលមិនមានវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មសាងសង់ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងចំពោះម្ចាស់សំណង់ ដែលដំណើរការការដ្ឋានសាងសង់ដោយមិនមានលិខិតអនុញ្ញាតចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវអភិបាល** ជ្រាប និងអនុវត្ត។

សូម **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត** ទទួលនូវការរាប់អានពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- មន្ទីរ ដនសស រាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋានៈ ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ /ទូរសារ (885) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com